Cambodian Overseas Support

**ONLINE LIBRARY**

(www.onekhmer.org/onlinelibrary)

**Title:** Basic Training on Climate Change and REDD+ for CSO-REDD+ Network's Members (Khmer)

| | |
|---|---|
| **Name of Author** | Nguon Pheakkdey |
| **Name of University** | Clark University |
| **Country of Study** | United States |
| **Major** | Human-Environment Geography |
| **Degree** | PhD |
| **Course Title** | |
| **Type of Document** | Government Newsletter |
| **Year** | 2014 |

REDD+ CAMBODIA

# ព្រឹត្តិបត្រប្រចាំត្រីមាស

លេខទី៥
ខែមិថុនា ឆ្នាំ២០១៤



*អ្នកចូលរួមក្នុងសិក្ខាសាលាបណ្ដុះបណ្ដាល ស្ដីពី ការប្រែប្រួលអាកាសធាតុ អភិបាលកិច្ចព្រៃឈើ និងរេដបូក ដែលបានរៀបចំឡើងកាលពីខែមេសា ឆ្នាំ២០១៤ (រូបភាព៖ FFI)*

## សិក្ខាសាលាបណ្ដុះបណ្ដាល ស្ដីពី ការប្រែប្រួលអាកាសធាតុ និងរេដបូក សម្រាប់សមាជិកបណ្ដាញសង្គមស៊ីវិលរេដបូក

ដើម្បីអនុវត្តរេដបូកប្រកបដោយប្រសិទ្ធភាព វាជាការចាំបាច់ដែលត្រូវការការចូលរួមពីក្រុមអ្នកពាក់ព័ន្ធជាច្រើន ជាពិសេសអង្គការសង្គមស៊ីវិល។ ក្រុមសង្គមស៊ីវិលមួយក្រុម ត្រូវបានដាក់ឱ្យចូលរួមយ៉ាងសកម្ម ក្នុងការងារអនុវត្តផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា។

ក្រុមសង្គមស៊ីវិលនេះមានសមាជិក២៦នាក់ដែលបានបង្កើតជាបណ្ដាញការងារមួយ របស់សង្គមស៊ីវិលសម្រាប់រេដបូក។ ក្រុមនេះ ចូលរួម និងអនុវត្តសកម្មភាពយ៉ាងសកម្មក្នុងការងារគោលនយោបាយរេដបូក និងវិធានការនានា ក្នុងដំណាក់កាលរៀបចំការត្រៀមលក្ខណៈសម្រាប់រេដបូក។ តែទោះជាយ៉ាងនេះក្ដី ចំណេះដឹង និងសមត្ថភាពរបស់សមាជិកខ្លះក្នុងក្រុមនៅមានកម្រិតនៅឡើយ ដែលធ្វើឱ្យពួកគាត់មិនអាចរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ ជាមួយតំណាងពួកគាត់នៅតាមខេត្តបាននៅឡើយ។ ហើយជាលទ្ធផលវាជាការលំបាកក្នុងការផ្ដល់អនុសាសន៍ដល់ស្ថាប័នរេដបូកកម្ពុជា (ឧ. ក្រុមការងាររេដបូក និងក្រុមការងារបច្ចេកទេសទាំងបួន)។ អាស្រ័យហេតុនេះ វគ្គបំពាក់បំប៉នមូលដ្ឋានស្ដីពី ការប្រែប្រួលអាកាសធាតុអភិបាលកិច្ចព្រៃឈើ និងរេដបូក ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី៧-៩ ខែមេសា ឆ្នាំ២០១៤ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុនកន្លងទៅ។

សិក្ខាសាលាបណ្ដុះបណ្ដាលនេះ មានសិក្ខាកាមចូលរួមចំនួន ៣០នាក់ក្នុងនោះមានស្ត្រីចំនួន៩នាក់។ សិក្ខាសាលាបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ។ សិក្ខាកាមបានពិភាក្សា រៀនសូត្រពីគ្នាទៅវិញទៅមក និងបានយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងទស្សនទានរេដបូកសំខាន់ៗ ដូចជា សុវត្ថិភាពសង្គម និងបរិស្ថាន ការបែងចែកផលប្រយោជន៍ មូលហេតុបាត់បង់ និងរេចរិលព្រៃឈើ ការវាស់ស្ទង់ ការរាយការណ៍ និងការផ្ទៀងផ្ទាត់ (MRV) និងបញ្ហាយេនឌ័រក្នុងបរិបទរេដបូក។

គេរំពឹងថាចំណេះដឹង និងជំនាញដែលបានផ្ដល់ជូននឹងអាចជួយជំរុញសមាជិកក្រុមសង្គមស៊ីវិល ចូលរួមក្នុងការងារពិគ្រោះយោបល់អំពីគោលនយោបាយរេដបូក និងក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តឲ្យកាន់តែសកម្ម និងមានប្រសិទ្ធភាព។

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ងួន ភក្ដី និង កញ្ញា តេង រិទ្ធីនី*

### មាតិកា

◊ មូលនិធិភាពជាដៃគូកាបូនព្រៃឈើ ............ ២
◊ ការវាយតម្លៃភាពជាស្រេចនៃរេដបូកកម្ពុជា ............ ៣
◊ មូលហេតុដែលបណ្ដាលឱ្យមានការបាត់បង់... ............ ៣
◊ របាយការណ៍វាយតម្លៃលើកទី៥របស់IPCC ............ ៤

# តើនរណាខ្លះអនុវត្តរេដបូកកម្ពុជា?




*អ្នកចូលរួមក្នុងសិក្ខាសាលាចាប់ផ្តើមគម្រោង FCPF*
*(រូបភាព៖ RTS)*

## មូលនិធិភាពជាដៃគូកាបូនព្រៃឈើ

មូលនិធិភាពជាដៃគូកាបូនព្រៃឈើ (FCPF) គឺជាគំនិតផ្តួចផ្តើមមួយរបស់ធានាគារពិភពលោក។ កម្មវិធីនេះបានចាប់ផ្តើមសកម្មភាពរបស់ខ្លួននៅខែមិថុនា ឆ្នាំ២០០៨។ FCPF ជួយបណ្តាប្រទេសកំពុងអភិវឌ្ឍនានា ក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ ការអភិរក្សព្រៃឈើ ការងារគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព និងការកែលម្អស្តុកកាបូន (គ្រប់សកម្មភាពទាំងអស់គឺសំដៅដល់រេដបូក) តាមរយៈការផ្តល់តម្លៃដល់ព្រៃឈើឈរ។

នៅកម្ពុជា FCPF ត្រូវបានអនុវត្តតាមរយៈអង្គការអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា (UNDP) ក្នុងនាមជាអ្នកផ្តល់សេវាកម្ម។ FCPF ជួយគាំទ្រដល់ការអនុវត្តផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា។ ក្នុងន័យនេះ FCPF ធ្វើការយ៉ាងជិតស្និទជាមួយអ្នកផ្តួចផ្តើមរេដបូកថ្នាក់ជាតិដទៃទៀត ដូចជាCAM-REDDនិងកម្មវិធី UN-REDD ជាដើម។គំនិតផ្តួចផ្តើមទាំងនេះ សម្រេចបាននូវលទ្ធផលបួនសំខាន់ៗ ដើម្បីនាំកម្ពុជាឱ្យមានលក្ខណៈត្រៀមជាស្រេចសម្រាប់អនុវត្តរេដបូក៖

លទ្ធផលទី១- ការគ្រប់គ្រងថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាពលើដំណើរការភាពជាស្រេចនៃរេដបូក និងការទាក់ទាញអ្នកពាក់ព័ន្ធស្របតាមគោលការណ៍ផែនទីបង្ហាញផ្លូវ។

លទ្ធផលទី២- ការបង្កើតយុទ្ធសាស្ត្ររេដបូកថ្នាក់ជាតិ និងការអនុវត្តក្របខ័ណ្ឌការងារ។

លទ្ធផលទី៣- លើកកម្ពស់សមត្ថភាពដើម្បីគ្រប់គ្រងរេដបូកនៅថ្នាក់ក្រោមជាតិ។

លទ្ធផលទី៤-ការរៀបចំប្រព័ន្ធត្រួតពិនិត្យនិងសមត្ថភាពសម្រាប់ការអនុវត្ត។

ស្ថិតក្នុងក្របខ័ណ្ឌការងារនេះFCPFបន្តស្វែងរកការគាំទ្រដល់ស្ថាប័នថ្នាក់ជាតិ ដូចជា ក្រុមការងាររេដបូក លេខាធិការដ្ឋានរេដបូក និងក្រុមប្រឹក្សារេដបូក ផ្តួចផ្តើមយុទ្ធសាស្ត្ររេដបូកសាកល្បងនៅតាមប្រភេទព្រៃសំខាន់ៗនៅកម្ពុជា ដាក់បញ្ចូលការអនុវត្តគម្រោងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងដាក់ឱ្យដំណើរការប្រព័ន្ធMRV និងប្រព័ន្ធត្រួតពិនិត្យជាតិ។

*សម្រាប់ព័ត៌មានបន្ថែម៖ http://www.cambodia-redd.org/category/supporting-redd-framework/fcpf#sthash.lThgh8xi.dpuf*

## ព្រឹត្តិការណ៍នាពេលខាងមុខ

**កិច្ចប្រជុំលើកទី៨នៃក្រុមប្រឹក្សាភិបាលកម្មវិធី, ០៧ សីហា ២០១៤**

កិច្ចប្រជុំនេះ នឹងរួមមានការពិភាក្សាបើកទូលាយនៅពេលថ្ងៃ ដែលដៃគូអនុវត្តនៃកម្មវិធីរេដបូកកម្ពុជា នឹងត្រូវបានអញ្ជើញឲ្យចូលរួម។ ដៃគូអនុវត្តនឹងត្រូវបានអញ្ជើញផងដែរ ក្នុងការរៀបចំសម្ភារៈការងារដែលបានបង្កើតឡើង ដើម្បីដាក់តាំងក្នុងថ្ងៃនៃកិច្ចប្រជុំ។ កិច្ចប្រជុំនេះក៏មានការពិភាក្សាពីប្រភេទទៅលើបញ្ហាទាំងឡាយដែលទាក់ទងនឹងគម្រោងអនុវត្ត ដែលដៃគូអភិវឌ្ឍមួយចំនួននឹងត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញជាសង្ខេប។

**កិច្ចប្រជុំ ស្តីពី ការពិនិត្យលើសម្ភារៈទំនាក់ទំនង, កក្កដា ២០១៤**

បន្ទាប់ពីរយៈពេល៩ខែ ក្នុងការរៀបចំនូវសម្ភារៈទំនាក់ទំនងរួមសម្រាប់ការប្រើប្រាស់ដោយដៃគូអនុវត្តទាំងឡាយ ក្នុងការលើកកម្ពស់ចំណេះដឹងអំពីរេដបូកសម្ភារៈទំនាក់ទំនងមួយចំនួនធំត្រូវបានរៀបចំដើម្បីធ្វើការបោះពុម្ពផ្សព្វផ្សាយ រួមមាន៖ វីដេអូ និងផ្ទាំងរូបភាពអប់រំ ខិតប័ណ្ណនិងសម្ភារៈអប់រំផ្សេងៗ។កិច្ចប្រជុំនេះនឹងធ្វើឡើងដោយមានការចូលរួមនៃក្រុមបច្ចេកទេសទាំងបួនដើម្បីធានាថាសម្ភារៈទាំងនេះគឺមានភាពស្របទៅនឹងគោលបំណង និងត្រឹមត្រូវ ដើម្បីធ្វើការអនុម័តក្នុងការបោះពុម្ពផ្សព្វផ្សាយ។

### ព័ត៌មានទំនាក់ទំនងសមាជិករេដបូកនៅកម្ពុជា


ប្រធានក្រុមការងាររេដបូក៖ **ឯ.ឧ ជា សំអាង**

◊ អ៊ីមែល៖ samangfa@gmail.com

អនុប្រធានក្រុមការងាររេដបូក៖ **លោក គឹម ណុង**

◊ អ៊ីមែល៖ kimnongmoe@yahoo.com

ប្រធានលេខាធិការដ្ឋានក្រុមការងាររេដបូក៖ **លោក ឃុន វឌ្ឍនា**

◊ អ៊ីមែល៖ vathana.khun@gmail.com

អនុប្រធានលេខាធិការដ្ឋានក្រុមការងាររេដបូក៖ **លោក អ៊ុយ កាម៉ាល់**

◊ អ៊ីមែល៖ kamaluy@yahoo.com

អ្នកសម្របសម្រួលកម្មវិធីរេដបូកកម្ពុជា៖ **លោក លន់ គឹមហ៊ី**

◊ អ៊ីមែល៖ kimhy.lun@undp.org

មន្ត្រីផ្នែកទំនាក់ទំនងកម្មវិធីរេដបូកកម្ពុជា៖ **កញ្ញា ធី ហៀង**

◊ អ៊ីមែល៖ heang.thy@undp.org

ប្រធានក្រុមប្រឹក្សាយោបល់រេដបូក៖ **លោកបណ្ឌិត សៀក សុផាត**

◊ អ៊ីមែល៖ seak.sophat@rupp.edu.kh

អនុប្រធានក្រុមប្រឹក្សាយោបល់រេដបូក៖ **លោក សារ ថ្លៃ**

◊ អ៊ីមែល៖ sathlay@yahoo.com

# ស្វែងយល់អំពីរេដបូក

## ស្ថានភាពការត្រៀមលក្ខណៈសម្រាប់រេដបូក៖ តើកម្ពុជាត្រូវបានប្រៀបធៀបដូចម្តេច ?

នៅចុងឆ្នាំ២០១៣ កម្មវិធីUN-REDD បានធ្វើការវាយតម្លៃមួយលើភាពជាស្រេចនៃរេដបូក នៅក្នុងប្រទេសចំនួន២៤ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ នៅក្នុងការវាយតម្លៃនេះ មានការងារសិក្សាស្ទាប់ស្ទង់ចំនួនពីរ គឺទីមួយការសិក្សាជាមួយជនបង្គោលរេដបូកថ្នាក់ជាតិ ដើម្បីវាយតម្លៃថាតើមានអ្វីខ្លះត្រូវបានសម្រេចនាពេលកន្លងមក និងមួយទៀតគឺធ្វើការជាមួយអ្នកពាក់ព័ន្ធ ដើម្បីវាយតម្លៃថាតើពួកគាត់មានអារម្មណ៍យ៉ាងណា និងថាតើពួកគាត់បានដឹងអំពីការត្រៀមលក្ខណៈសម្រាប់រេដបូក បានកម្រិតណា។

ដោយសារការត្រៀមលក្ខណៈសម្រាប់រេដបូក គ្របដណ្តប់លើច្រើនបញ្ហា វាជាការលំបាកមួយក្នុងការវាយតម្លៃ។ ប្រទេសមួយប្រហែលជាអាចសម្រេចបានលទ្ធផលជាដុំកំភួន ជាមួយនឹងផ្នែកមួយ ហើយសម្រេចបានតិចតួចនៅលើផ្នែកដទៃទៀត។ លទ្ធផលបានពីការស្ទាប់ស្ទង់ជាមួយជនបង្គោល បានបង្ហាញ ៦ចំណុច សំខាន់ៗ ដូចខាងក្រោម៖




ដ្យាក្រាមនេះបង្ហាញថាកម្ពុជាមានចំណុចល្អជាច្រើនបើប្រៀបធៀបនៅក្នុងថ្នាក់តំបន់គិតជាមធ្យម ប៉ុន្តែនៅមានការយឺតយ៉ាវលើចំណុចមួយចំនួនដូចជាការរៀបចំយុទ្ធសាស្ត្រនិងការងារត្រួតពិនិត្យ/MRV។ កម្ពុជាមានចំនួនអ្នកឆ្លើយតបខ្ពស់បំផុត ពីការស្ទាប់ស្ទង់ជាមួយអ្នកពាក់ព័ន្ធ ពោលគឺបានទទួលចម្លើយឆ្លើយតបចំនួន៥៦ ក្នុងចំណោមមនុស្សច្រើនជាង១៦០នាក់ ដែលត្រូវបានអញ្ជើញឱ្យចូលរួមឆ្លើយនឹងកម្រងសំណួរ។ អ្នកពាក់ព័ន្ធ ត្រូវបានវាយតម្លៃទៅលើចំណេះដឹង និងទស្សនទាន។ លទ្ធផលមួយ ដែលគួរឱ្យកត់សម្គាល់សម្រាប់កម្ពុជាបើធៀបជាមួយប្រទេសទាំងអស់ គឺកម្ពុជាមានអត្រាអ្នកចូលរួមខ្ពស់បំផុតដែលបានសំដែងអារម្មណ៍"ពេញចិត្តខ្លាំង"ជាមួយនឹងកម្រិតចូលរួមរបស់ពួកគេ។

ក្នុងបរិបទចំណេះដឹង លទ្ធផលមានលក្ខណៈចម្រុះ។ អ្នកពាក់ព័ន្ធជាច្រើនមិនបានដឹងអំពីអនុសញ្ញា អន្តរជាតិដែលកម្ពុជា ជាសមាជិក ហើយមានតែប្រទេសថៃ និងប្រទេសវ៉ាណាទូទេ ដែលមានពិន្ទុទាប




ជាងនេះ។ ម្យ៉ាងវិញទៀត ចំណេះដឹងភាគីអ្នកពាក់ព័ន្ធអំពីការរៀបចំនៃការត្រៀមលក្ខណៈសម្រាប់រេដបូកគឺល្អណាស់ ហើយមានតែ បួនប្រទេសប៉ុណ្ណោះ(ឥណ្ឌា,ម៉ាឡេស៊ី,នេប៉ាល់,និងវៀតណាម)ដែលបានពិន្ទុខ្ពស់ជាង។ លើបញ្ហាបច្ចេកទេស ដូចជា យុទ្ធសាស្ត្ររេដបូក និងការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ ចំណេះដឹងរបស់អ្នកពាក់ព័ន្ធ គឺមានពិន្ទុមធ្យម។

អត្ថបទនេះ គឺបង្ហាញតែលទ្ធផលដែលចាប់អារម្មណ៍មួយចំនួនប៉ុណ្ណោះ ពីរបាយការណ៍ដែលបានធ្វើការវាយតម្លៃ ប៉ុន្តែជាទូទៅកម្ពុជាហាក់ដូចជាមានការវិវឌ្ឍល្អ ទៅនឹងការត្រៀមលក្ខណៈសម្រាប់រេដបូកដែលមានការចូលរួមល្អពីអ្នកពាក់ព័ន្ធនានា។ ក្នុងពេលឆាប់ៗខាងមុខលទ្ធផលសិក្សាទាំងមូលនេះ នឹងដាក់ផ្សាយនៅលើគេហទំព័ររបស់ UN-REDD ៖ http://www.un-redd.org/ ។

## ការដោះស្រាយមូលហេតុដែលនាំឱ្យមានការបាត់បង់ និងរេចរឹលព្រៃឈើនៅកម្ពុជា

កាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៤ រដ្ឋបាលព្រៃឈើ ជាមួយនឹងកម្មវិធីUN-REDD អង្គការJICA និងកម្មវិធីគាំទ្រព្រៃឈើ និងជីវចម្រុះនៃភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID)នៅកម្ពុជា និងកម្មវិធីកាត់បន្ថយការបញ្ចេញឧស្ម័នពីព្រៃឈើនៅតំបន់អាស៊ី (LEAF) គាំទ្រដោយ USAID បានសហការរៀបចំសិក្ខាសាលាមួយ ស្តីពី មូលហេតុដែលបណ្តាលឱ្យមានការបាត់បង់ និងរេចរឹលព្រៃឈើ នៅទីក្រុងភ្នំពេញ។ សិក្ខាសាលានេះ មានសិក្ខាកាមចូលរួមចំនួន៥៨នាក់ និងត្រូវបានរៀបចំឡើងនូវដំណើរការមួយដើម្បីវាយតម្លៃការបាត់បង់ និងរេចរឹលព្រៃឈើនៅកម្ពុជា និងកំណត់មូលហេតុចម្បងៗរបស់វា ដែលជាជំហានសំខាន់មួយក្នុងការកំណត់យុទ្ធសាស្ត្រសហការដើម្បីកាត់បន្ថយការបាត់បង់និងរេចរឹលព្រៃឈើ។

សិក្ខាសាលា បានប្រើប្រាស់សេចក្តីព្រាងវិធានជួយសម្រេចចិត្តមួយ ស្តីពី ការកំណត់ និងដោះស្រាយមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ ដែលវិធាននេះបានរៀបចំឡើងដោយកម្មវិធីបណ្តាញចំណេះដឹងតំបន់អាស៊ាន ស្តីពី ព្រៃឈើ និងការប្រែប្រួលអាកាសធាតុក្រោមជំនួយឧបត្ថម្ភពី USAID LEAF។

លើសពីនេះទៅទៀត សិក្ខាសាលាបានផ្តល់វិធានណែនាំក្នុងការវាយតម្លៃអំពីមូលហេតុដែលបណ្តាល ឱ្យមានការបាត់បង់ និងរេចរឹលព្រៃឈើនៅកម្ពុជា។ សិក្ខាសាលាក៏បានផ្តល់ឱកាសសម្រាប់មន្ត្រីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដើម្បីវាយតម្លៃលើវិធានជួយសម្រេចចិត្តមួយ ស្តីពី ការកំណត់ និងដោះស្រាយមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ និងដើម្បីប្រមូលមតិយោបល់សម្រាប់ដាក់ជូនទៅបណ្តាញការងារអាស៊ានវិញ។ សិក្ខាសាលានេះបានជួយគាំទ្រធាតុសំខាន់របស់យុទ្ធសាស្ត្ររេដបូក និងផែនទីបង្ហាញផ្លូវ ហើយវាក៏ជាផ្នែកមួយរបស់ USAID/ LEAF ក្នុងការកៀរគរសកម្មភាពនានាផងដែរ សម្រាប់ដោះស្រាយមូលហេតុបាត់បង់ និងរេចរឹលព្រៃឈើនៅក្នុងតំបន់។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ហ៊ួ លីមឈុន អ្នកសម្របសម្រួលប្រចាំកម្ពុជាតាមរយៈអ៊ីម៉ែល limchhun@winrock.org ។

# របាយការណ៍វាយតម្លៃលើកទី៥ របស់ IPCC



*វគ្គបណ្តុះបណ្តាល និងសាកល្បងលើកទីមួយ ស្តីពី សារពើភ័ណ្ឌព្រៃឈើជាតិ (NFI) នៅខែកុម្ភៈ ឆ្នាំ២០១៤ នៅខេត្តសៀមរាប ដែលរៀបចំដោយ FAO TCP CMB 3304 (រូបភាព៖ FAO/UN-REDD)*

ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ( IPCC ) គឺជាស្ថាប័នអន្តរជាតិមួយ ទទួលបន្ទុកលើការវាយតម្លៃវិទ្យាសាស្ត្រ អំពីការប្រែប្រួលអាកាសធាតុ។ របាយការណ៍វាយតម្លៃពិស្តារមួយប្រកបដោយវិទ្យាសាស្ត្រ ត្រូវបានរៀបចំឡើងរៀងរាល់ ៤ ឬ ៥ ឆ្នាំម្តង ហើយរបាយការណ៍នេះ គឺទាក់ទងខ្លាំងទៅនឹងកិច្ចប្រឹងប្រែងរបស់អន្តរជាតិ ក្នុងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ របាយការណ៍វាយតម្លៃលើកទី៥ គឺកំពុងត្រូវបានផ្សព្វផ្សាយក្នុងឆ្នាំនេះ ហើយមកដល់បច្ចុប្បន្នយើងបានឃើញរបាយការណ៍នេះ មានបីផ្នែក គឺផ្នែកទី១-មូលដ្ឋានវិទ្យាសាស្ត្ររូប ទី២-ផលប៉ះពាល់ការបន្សាំ និងភាពងាយរងគ្រោះ ទី៣-ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

របាយការណ៍នេះបានគូសបញ្ជាក់អំពីផលវិបាកធ្ងន់ធ្ងរដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ។ ព្រៃឈើ និងការប្រើប្រាស់ដីដើរតួរយ៉ាងសំខាន់ក្នុងការប្រែប្រួលនេះ ដោយវាបានបញ្ចេញឧស្ម័នកាបូនិចប្រហែល១០%នៃបរិមាណបញ្ចេញឧស្ម័នកាបូនិចសរុបរបស់ពិភពលោកពីការបាត់បង់ព្រៃឈើ គិតពីឆ្នាំ២០០២ ដល់ ២០១១។ ក្នុងរយៈពេលដូចគ្នាដែរ ផ្នែកព្រៃឈើ និងការប្រើប្រាស់ដីដទៃទៀតបានស្រូបយកឧស្ម័នកាបូនិច ២៧% នៃបរិមាណសរុបតាមរយៈការស្រូបដោយរុក្ខជាតិ ហើយជាលទ្ធផលវាជួយកាត់បន្ថយបរិមាណឧស្ម័នកាបូនិចពីបរិយាកាស។

នៅពេលរុក្ខជាតិត្រូវការឧស្ម័នកាបូនិចដើម្បីលូតលាស់ ការប្រែប្រួលអាកាសធាតុអាចជាគ្រោះថ្នាក់មួយចំពោះប្រព័ន្ធអេកូឡូស៊ីព្រៃឈើ។ នៅតំបន់ត្រូពិច ត្រូវទទួលរងផលប៉ះពាល់តាមរយៈការព្យាករណ៍អំពីកំណើនបាតុភូតរាំងស្ងួតកាន់តែខ្លាំង ហើយបាតុភូតនេះរួមគ្នាជាមួយនឹងបម្រែបម្រួលការប្រើប្រាស់ដី និងភ្លើងឆេះព្រៃ ត្រូវបានគេព្យាករណ៍ថានឹងបណ្តាលឱ្យប៉ះពាល់ខ្លាំងលើព្រៃអាម៉ាហ្សូន តាមរយៈការបំប្លែងតំបន់នោះឱ្យទៅជាប្រព័ន្ធអេកូឡូស៊ីមួយ ដែលមានព្រៃស្តើងជាងមុន និងមានលក្ខណៈបន្សាំបានជាមួយនឹងភាពរាំងស្ងួត និងភ្លើងព្រៃ។ ជីវម៉ាស់ និងស្តុកកាបូននៅក្នុងប្រព័ន្ធអេកូឡូស៊ីដីគោក នាពេលបច្ចុប្បន្នកំពុងតែកើនឡើង ប៉ុន្តែវាមានភាពងាយរងគ្រោះក្នុងការបាត់បង់ទៅក្នុងបរិយាកាស ដោយសារកំណើនសីតុណ្ហភាព គ្រោះរាំងស្ងួត និងភ្លើងឆេះព្រៃ ដូចបានព្យាករណ៍សម្រាប់សតវត្សទី២១នេះ។

បរិមាណស្តីពីការកាត់បន្ថយឧស្ម័ន បានគូសបញ្ជាក់អំពីមុខនាទីសំខាន់របស់ព្រៃឈើដែលវាអាចដើរតួក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ពោលគឺតាមរយៈរេដបូក។ របាយការណ៍បានបរិយាយអំពីអត្រាបាត់បង់ព្រៃឈើនៅតំបន់អាម៉ាហ្សូន ក្នុងប្រទេសប្រេស៊ីលថាបានធ្លាក់ចុះ ៧៧% ក្រោមកម្រិតមធ្យមរបស់វា ដោយគិតក្នុងអំឡុងពេលពីឆ្នាំ ១៩៩៦-២០០៥ ដោយសារមានសញ្ញាប្រែប្រួលគោលនយោបាយ និងទីផ្សារ។ និន្នាការមួយនេះ តំណាងឱ្យការកាត់បន្ថយការបញ្ចេញឧស្ម័នពិភពលោក ដែលកើតឡើងពីសកម្មភាពមនុស្សបាន១,5%។

IPCC បានសន្និដ្ឋានថា ការកាត់បន្ថយឧស្ម័នដែលពាក់ព័ន្ធនឹងដី និងជីវៈថាមពលអាចរួមចំណែកពី២០%ទៅ៦០%នៃបរិមាណកាត់បន្ថយសរុបនៅឆ្នាំ ២០៣០។ បញ្ហាលើការសម្របសម្រួល និងការអនុវត្តផ្នែកគោលនយោបាយ គឺជាឧបសគ្គក្នុងការធ្វើឱ្យទទួលស្គាល់នូវសក្តានុពលនេះ។

របាយការណ៍វាយតម្លៃលើកទី៥ អាចរកបានតាមរយៈគេហទំព័រ៖ http://www.ipcc.ch/report/ar5/

## បច្ចុប្បន្នភាពនៃគេហទំព័ររបស់រេដបូកកម្ពុជា

*សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅគេហទំព័ររេដបូកកម្ពុជា៖* **www.cambodia-redd.org** *។ ព័ត៌មានដែលបានដាក់បញ្ចូលថ្មីៗ៖*

- *កូនសៀវភៅស្តីពីសេចក្តីសម្រេចចិត្តពីកិច្ចប្រជុំបណ្តាប្រទេសជាភាគី*
- *របាយការណ៍វិភាគស្តីពី យេនឌ័រ និងរេដបូក*
- *ឯកសារកិច្ចប្រជុំក្រុមការងារលើកទីប្រាំ*
- *ឯកសារកិច្ចប្រជុំក្រុមប្រឹក្សាយោបល់លើកទីប្រាំមួយ*

*ព័ត៌មានលម្អិតមានជូនពិស្តារនៅក្នុង៖*
**http://www.cambodia-redd.org/category/document-centre**

## ព័ត៌មានទំនាក់ទំនងលេខាធិការដ្ឋានរេដបូកកម្ពុជា

**លោក ឃុន វឌ្ឍនា**
ប្រធានលេខាធិការដ្ឋានក្រុមការងាររេដបូក
#៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ភ្នំពេញ កម្ពុជា
លេខទូរស័ព្ទ៖ (+៨៥៥) ២៣ ២២៤ ២៥១
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org